# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## លទ្ធផលនៃកិច្ចប្រជុំថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ដើម្បីដោះស្រាយវិវាទការងារ នៅក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត

ស្របតាមស្មារតីកិច្ចប្រជុំនៅសាលារាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ ដែលអង្គប្រជុំបានឯកភាពគ្នាថា នឹងបន្តដោះស្រាយករណីទាមទាររបស់បងប្អូនកម្មករនិយោជិតនៃក្រុមហ៊ុនណាហ្គាវើលដ៍ លីមីធីត ចំនួន ៣៦០នាក់ ដែលមិនទាន់ឯកភាពក្នុងការទទួលយកការទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារទៅតាមករណីនីមួយៗ។

ក្នុងន័យនេះ ដើម្បីបន្តដោះស្រាយករណីវិវាទនេះ ស្របតាមច្បាប់ និងនីតិវិធីជាធរមាន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញលិខិតអញ្ជើញបងប្អូនកម្មករនិយោជិតទាំង ៣៦០នាក់ និងអ្នកតំណាងរបស់ខ្លួនមកធ្វើការដោះស្រាយ **ចាប់ពីម៉ោង ៩:០០នាទីព្រឹក ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ តទៅ នៅទីស្តីការក្រសួង**។ គិតត្រឹមម៉ោង ៤រសៀល នេះ មានកម្មករនិយោជិតម្នាក់បានមកចូលរួម និងបានជម្រាបក្រសួងថាខ្លួនឯកភាពទទួលយកដំណោះស្រាយពីក្រុមហ៊ុន និងត្រៀមខ្លួនជូនដំណឹងទៅក្រុមហ៊ុននៅថ្ងៃស្អែក ហើយពេលរសៀលនេះ ក្រសួងបានប្រជុំជាមួយតំណាងរបស់បងប្អូនកម្មករនិយោជិតដើម្បីពិនិត្យទៅលើការគណនាសំណងរបស់និយោជកកន្លងមក។

ក្រសួងបន្តរង់ចាំទទួលបងប្អូនកម្មករនិយោជិត ដែលយល់ព្រមទទួលយកលក្ខខណ្ឌដែលបានឯកភាពក្នុងកិច្ចប្រជុំនៅសាលារាជធានីភ្នំពេញកន្លងមក និងបន្តជួបជាមួយតំណាងបងប្អូនកម្មករនិយោជិតដើម្បីពិភាក្សាលើការងារផ្សេងៗ។ សូមបងប្អូន និងអង្គការសហជីព ក៏ដូចជានិយោជកចូលរួមសហការជាមួយក្រសួង និងអាជ្ញាធរមានសមត្ថកិច្ចដើម្បីបញ្ចប់ករណីវិវាទនេះ ជាជាងការធ្វើកូដកម្ម ដែលនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍គ្រប់ភាគីពាក់ព័ន្ធ។

ក្រសួងបន្តការពារឱ្យបាននូវអ្វីដែលជាផលប្រយោជន៍ស្របច្បាប់របស់បងប្អូនកម្មករនិយោជិត និងនិយោជក ព្រមទាំងបន្តខិតខំសម្របសម្រួលដោះស្រាយវិវាទការងារនេះជូនបងប្អូនជារៀងរាល់ថ្ងៃ ចាប់ពីម៉ោង ៩:០០ព្រឹក តទៅ ស្របតាមតួនាទីភារកិច្ចរបស់ខ្លួន រហូតករណីវិវាទនេះត្រូវបានដោះស្រាយបញ្ចប់ស្របតាមច្បាប់នានាជាធរមាន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមបងប្អូនកម្មករនិយោជិត និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន។ ក្រសួងនឹងជូនដំណឹងជាបន្តបន្ទាប់ទៀតក្នុងករណីមានវឌ្ឍនភាពនៅរៀងរាល់ពេលមានការជួបប្រជុំជាមួយតំណាងរបស់បងប្អូន ឬនៅពេលជួបជាមួយបងប្អូនណាមួយដោយផ្ទាល់។

*ថ្ងៃពុធ ៣រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥*

*រាជធានីភ្នំពេញ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១*

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨៤៣៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩*